អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងរៀបចំថ្នាក់ឱ្យមានរបៀប**
**ចិត្តចលភាព**
បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។
**បុរេគណិត**
ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)

**គោលបំណង**
**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាតាមបែបទម្រង់ផ្សេងៗ ដោយការធ្វើអ្វីមួយ ឬ ការលេងល្បែងផ្សេងៗ
**(បុរេគណិត)** ប្រាប់ពីរបៀបរៀបវត្ថុតាមលំដាប់តាមលំដាប់ តាមក្រុម តាមប្រភេទ ទំហំ និងពណ៌។
ដើម្បីឱ្យកុមារមានការយល់ដឹងពីរបៀបនៃការលេងរបស់អ្វីមួយ រួចត្រូវប្រមូលទុកដាក់វិញឱ្យមានរបៀបដូចដើម។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់
**រយៈពេល** ៖ ២០ នាទី
**ឧបករណ៍** ៖ ជ្រើសវត្ថុពីក្នុងថ្នាក់រៀន កំប៉ុង គម្របដប មែកឈើ ប្រអប់ សៀវភៅ ប៊ិច បន្ទាត់ រូបសូនសម្រាប់តាំង រូបភាពផ្សេងៗ.....។
**ការរៀបចំ** ៖ ពង្រាយវត្ថុជុំវិញក្នុងថ្នាក់រៀនជាលក្ខណៈគ្មានរបៀបរៀបរយ។

**សេចក្ដីណែនាំ៖**

1. ត្រូវពង្រាយវត្ថុមួយចំនួននៅក្នុងថ្នាក់រៀននៅពេលដែលក្មេងៗចេញលេង ។
2. នៅពេលដែលពួកគេត្រឡប់មកវិញ អ្នកអាចចាប់ផ្ដើមលេងបាន។
3. និយាយថា៖ តើកូនៗមួយណាធ្វើឱ្យថ្នាក់រៀនរញ៉េរញ៉ៃ?
   តើកូនៗណាអាចជួយរៀបចំឱ្យមានរបៀបឡើងវិញដែរឬទេ?
4. ប្រាប់ក្មេងៗថាត្រូវរៀបចំ នឹងបែងចែកវត្ថុទៅតាមប្រភេទ ក្រុម តាមពណ៌ តាមលំដាប់លំដោយ ដាក់តាមប្រអប់។
5. លោកអ្នកត្រូវពិចារណាពីវត្ថុទាំងនោះថាមានអ្វីខ្លះដែលអាចឱ្យក្មេងៗលេងបាន។
6. រួចបង្កើតជាក្រុមដើម្បីឱ្យកុមារលេងតាមក្រុម។